ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

**សូមគោរពជូន**

**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៧០ឆ្នាំ ឈានចូល ៧១ឆ្នាំ**

**សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៧០ឆ្នាំ ឈានចូល ៧១ឆ្នាំ របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** ដ៏ប្រសើរឧត្តុង្គឧត្តម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរក្រៃលែង និងការគោរពកោតសរសើរដោយស្មោះចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត** ដែលបាននិងកំពុងដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមចំណែកយ៉ាងសំខាន់ដល់ការរីកចម្រើនយ៉ាងឆាប់រហ័សនិងច្រើនឥតគណនាលើគ្រប់វិស័យទាំងអស់នៅកម្ពុជា ក៏ដូចជាជីវភាពសម្បូរសប្បាយរបស់ប្រជាជនកម្ពុជាសព្វថ្ងៃ។

ក្នុងឱកាសចម្រើនជន្មាយុរបស់ **សម្តេចកិត្តិសង្គហបណ្ឌិត** ដ៏ប្រសើរឧត្តុង្គឧត្តម យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានពរជ័យ បវរសួស្តី សិរីមង្គលគ្រប់ប្រការជូន **សម្តេចកិត្តិសង្គហបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមមានសុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនថ្មីៗថែមទៀត ពិសេសការធានាបាននូវសន្តិភាពជាតិដ៏រឹងមាំ ភាពសម្បូរសប្បាយរុងរឿង និងសុភមង្គលរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ព្រមទាំងក្រុមគ្រួសារ** សមប្រកបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**